**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់ប្រាក់រង្វាន់ចំពោះជ័យលាភី និងប្រាក់ឧបត្ថម្ភចំពោះគ្រូបង្វឹក ក្នុងការប្រកួតកីឡាជាលក្ខណៈអន្តរជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអូឡាំពិក សំរាប់ជនពិការ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១**: អនុក្រឹត្យនេះ មានគោលដៅកំណត់ការផ្តល់ប្រាក់រង្វាន់ចំពោះជ័យលាភី និងប្រាក់ឧបត្ថម្ភចំពោះគ្រូបង្វឹក ដើម្បីជាការលើកទឹកចិត្ត ក្នុងការប្រកួតកីឡាជាលក្ខណៈអន្តរជាតិ ។

**មាត្រា ២**: ការផ្តល់ប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភ ត្រូវអនុវត្តចំពោះការប្រកួតកីឡាជាលក្ខណៈអន្តរជាតិ នៅក្រៅប្រទេស និងនៅក្នុងប្រទេស ដែលកីឡាករកម្ពុជា ត្រូវបានអនុញ្ញាតឲ្យចូលរួម ។

**មាត្រា ៣**: វាក្យស័ព្ទសំខាន់ៗ ក្នុងអនុក្រឹត្យនេះ មានន័យដូចតទៅ ៖

- ការប្រកួតកីឡាជាលក្ខណៈអន្តរជាតិ សំដៅដល់ការប្រកួតជាលក្ខណៈហ្គេមបីកំរិត គឺការប្រកួតកីឡាអាស៊ីអាគ្នេយ៍ (SEA Games) ការប្រកួតកីឡាអាស៊ី (ASIAN Games) ការប្រកួតកីឡាអូឡាំពិក (OLYMPIC Games)
- ការប្រកួតកីឡាអូឡាំពិករដូវក្តៅ សំដៅដល់ការប្រកួតថ្នាក់ពិភពលោក ដែលស្ថិតក្រោមការចាត់ចែងរបស់គណៈកម្មាធិការអូឡាំពិកអន្តរជាតិ
- ការប្រកួតកីឡាអូឡាំពិករដូវរងារ សំដៅដល់ការប្រកួតថ្នាក់ពិភពលោក ដែលចាត់ចែង និងរៀបចំដោយគណៈកម្មាធិការអូឡាំពិកអន្តរជាតិ ដែលប្រព្រឹត្តទៅនៅបណ្តាប្រទេសមានទឹកកកធ្លាក់នៅរដូវរងារ
- ការប្រកួតកីឡាអាស៊ីរដូវក្តៅ សំដៅដល់ការប្រកួតកីឡាស្ថិតនៅក្នុងរង្វង់ទ្វីបអាស៊ី ដែលចាត់ចែង និងរៀបចំឡើងដោយក្រុមប្រឹក្សាអូឡាំពិកអាស៊ី
- ការប្រកួតកីឡាអាស៊ីរដូវរងារ សំដៅដល់ការប្រកួតកីឡារដូវរងារក្នុងរង្វង់ទ្វីបអាស៊ី ដែលចាត់ចែង និងរៀបចំឡើងដោយក្រុមប្រឹក្សាអូឡាំពិកអាស៊ី ហើយប្រភេទកីឡាដែលត្រូវដាក់ក្នុងកម្មវិធីប្រកួត ត្រូវស្ថិតនៅក្នុងកម្មវិធីរបស់ការប្រកួតកីឡាអូឡាំពិករដូវរងារដែរ
- ការប្រកួតកីឡាអាស៊ីអាគ្នេយ៍ សំដៅដល់ការប្រកួតដែលចាត់ចែង និងរៀបចំឡើងដោយសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ និងស្ថិតក្រោមបរិបាលកិច្ចនៃគណៈកម្មាធិការអូឡាំពិកអន្តរជាតិ និងក្រុមប្រឹក្សាអូឡាំពិកអាស៊ី
- កីឡាករ សំដៅដល់អ្នកកីឡា មានជំនាញក្នុងវិញ្ញាសារណាមួយ ជាបុរស ឬនារី ដែលត្រូវចាត់ឲ្យចូលរួមក្នុងការប្រកួតជាលក្ខណៈអន្តរជាតិ
- គ្រូបង្វឹក សំដៅដល់អ្នកកីឡា មានជំនាញក្នុងវិញ្ញាសារណាមួយ ជាបុរស ឬនារី ដែលត្រូវចាត់ឲ្យបង្វឹកត្រៀមនៅពេលប្រកួតជាលក្ខណៈអន្តរជាតិ
- ជ័យលាភី សំដៅដល់កីឡាករជាឯកត្តជន ឬជាក្រុម ដែលទទួលបានមេដាយ ក្នុងការប្រកួតជាលក្ខណៈអន្តរជាតិ
- និយាមអន្តរជាតិ សំដៅដល់ចំនួនកីឡាករ គ្រូបង្វឹក គ្រូបង្វឹកជំនួយ ដែលកំណត់ជាផ្លូវការដោយគណៈកម្មការរៀបចំហ្គេម ។

## ជំពូកទី ២
## ការផ្តល់ប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភ

**មាត្រា ៤**: ប្រាក់រង្វាន់ចំពោះជ័យលាភីឯកត្តជន ដែលទទួលបានមេដាយមាស មេដាយប្រាក់ និងមេដាយសំរិទ្ធ ត្រូវបានផ្តល់ ដូចខាងក្រោម ៖

| ល.រ. | ប្រភេទមេដាយ | ការប្រកួតកីឡាអូឡាំពិក រដូវក្តៅ ឬរដូវរងារ | ការប្រកួតកីឡាអាស៊ី រដូវក្តៅ ឬរដូវរងារ | ការប្រកួតកីឡា អាស៊ីអាគ្នេយ៍ |
|---|---|---|---|---|
| ១ | មេដាយ មាស | ១២០ ០០០ ០០០ រៀល | ៨០ ០០០ ០០០ រៀល | ៤០ ០០០ ០០០ រៀល |
| ២ | មេដាយ ប្រាក់ | ៨០ ០០០ ០០០ រៀល | ៤០ ០០០ ០០០ រៀល | ៣០ ០០០ ០០០ រៀល |
| ៣ | មេដាយ សំរិទ្ធ | ៦៤ ០០០ ០០០ រៀល | ២៤ ០០០ ០០០ រៀល | ១៦ ០០០ ០០០ រៀល |

**មាត្រា ៥**: ចំពោះការប្រកួតដែលមានកីឡាករជាក្រុម ហើយទទួលបានមេដាយ ប្រាក់រង្វាន់ជ័យលាភីជាក្រុម ត្រូវបានផ្តល់អោយដោយយកប្រាក់រង្វាន់សម្រាប់ជ័យលាភីម្នាក់ៗ ក្នុងមាត្រា ៤ គុណនឹងចំនួនកីឡាករ ដែលបានចូលរួមប្រកួត តាមនិយាមអន្តរជាតិ ។

**មាត្រា ៦**: គ្រូបង្វឹកត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភ ស្មើនឹងប្រាក់រង្វាន់របស់ជ័យលាភី ដែលទទួលបានចំណាត់ថ្នាក់មេដាយខ្ពស់ជាងគេ ក្នុងវិញ្ញាសាប្រកួតក្នុងក្រុម ដែលខ្លួនទទួលបន្ទុកបង្វឹក ។
គ្រូបង្វឹកជំនួយ ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន ៧០% នៃប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក ។

**មាត្រា ៧**: ជ័យលាភីឯកត្តជន ឬជាក្រុម ក្នុងការប្រកួតកីឡាជាលក្ខណៈអន្តរជាតិ ក្រៅពីការប្រកួត ដូចមានចែងក្នុងមាត្រា ៣ ត្រូវបានផ្តល់ប្រាក់រង្វាន់តាមប្រកាសអន្តរក្រសួង ស្តីពីគោលការណ៍សម្រាប់ហ្វឹកហាត់ និងការប្រកួតកីឡាជាផ្លូវការគ្រប់ប្រភេទ ប្រចាំឆ្នាំ ។

## ជំពូកទី ៣
## ការផ្តល់ប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភ ចំពោះកីឡាករជនពិការ

**មាត្រា ៨**: ការផ្តល់ប្រាក់រង្វាន់ និងប្រាក់ឧបត្ថម្ភ ត្រូវអនុវត្តចំពោះការប្រកួតកីឡាជាលក្ខណៈអន្តរជាតិ នៅក្រៅប្រទេស និងនៅក្នុងប្រទេស ដែលកីឡាករជនពិការកម្ពុជា ត្រូវអនុញ្ញាតឲ្យចូលរួម ។

**មាត្រា ៩**: វាក្យស័ព្ទសំខាន់ៗក្នុងជំពូកនេះ មានន័យដូចតទៅ ៖

- កីឡាករជនពិការ សំដៅដល់អ្នកកីឡាជាបុរស ឬនារី ដែលមានពិការភាព រួមទាំងពិការបញ្ញាខ្សោយដែលត្រូវចាត់ឲ្យចូលរួមក្នុងការប្រកួតជាលក្ខណៈអន្តរជាតិ
- ការប្រកួតជាលក្ខណៈអន្តរជាតិ របស់កីឡាករជនពិការ សំដៅដល់ការប្រកួតជាលក្ខណៈហ្គេមបីកម្រិត គឺការប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេម (ASEAN Para Games) ការប្រកួតកីឡាអាស៊ីប៉ារ៉ាហ្គេម (ASIAN Para Games) ការប្រកួតកីឡាប៉ារ៉ាឡាំពិក (IPC Games)
- ការប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេម សំដៅដល់ការប្រកួតកីឡាស្ថិតនៅក្នុងរង្វង់តំបន់អាស៊ីអាគ្នេយ៍ដែលចាត់ចែងនិងរៀបចំឡើងដោយក្រុមប្រឹក្សាសហព័ន្ធកីឡាជនពិការអាស៊ាន (APSF)
- ការប្រកួតកីឡាអាស៊ីប៉ារ៉ាហ្គេមរដូវក្តៅ ឬរដូវរងារ សំដៅដល់ការប្រកួតកីឡាក្នុងរង្វង់ទ្វីបអាស៊ីដែលចាត់ចែង និងរៀបចំឡើងដោយក្រុមប្រឹក្សាកីឡាជនពិការអាស៊ី (APC)

- ការប្រកួតកីឡាប៉ារ៉ាឡាំពិកហ្គេមរដូវក្តៅ ឬរដូវរងារ សំដៅដល់ការប្រកួតដែលចាត់ចែង និងរៀបចំឡើងដោយគណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ (IPC)
- ជ័យលាភី សំដៅដល់កីឡាករជនពិការជាឯកត្តជន ឬជាក្រុមដែលទទួលបានមេដាយក្នុងការប្រកួតជាលក្ខណៈអន្តរជាតិ
- និយាមអន្តរជាតិ សំដៅដល់ចំនួនកីឡាករជនពិការ គ្រូបង្វឹក គ្រូបង្វឹកជំនួយ ដែលកំណត់ជាផ្លូវការដោយគណៈកម្មការរៀបចំហ្គេម ។

**មាត្រា ១០**: ប្រាក់រង្វាន់ ចំពោះជ័យលាភីសម្រាប់កីឡាករជនពិការឯកត្តជន ដែលទទួលបានមេដាយមាស មេដាយប្រាក់ និងមេដាយសំរិទ្ធ ត្រូវបានផ្តល់ ដូចខាងក្រោមនេះ ៖

| ល.រ. | ប្រភេទមេដាយ | ការប្រកួតកីឡាប៉ារ៉ាឡាំពិកហ្គេម រដូវក្តៅ ឬរដូវរងារ | ការប្រកួតកីឡាអាស៊ីប៉ារ៉ាហ្គេម រដូវក្តៅ ឬរដូវរងារ | ការប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេម |
|---|---|---|---|---|
| ១ | មេដាយ មាស | ១២០ ០០០ ០០០ រៀល | ៨០ ០០០ ០០០ រៀល | ៤០ ០០០ ០០០ រៀល |
| ២ | មេដាយ ប្រាក់ | ៨០ ០០០ ០០០ រៀល | ៤០ ០០០ ០០០ រៀល | ៣០ ០០០ ០០០ រៀល |
| ៣ | មេដាយ សំរិទ្ធ | ៦៤ ០០០ ០០០ រៀល | ២៤ ០០០ ០០០ រៀល | ១៦ ០០០ ០០០ រៀល |

**មាត្រា ១១**: -ប្រាក់រង្វាន់សម្រាប់កីឡាករជនពិការជាក្រុម អនុវត្តដូចមាត្រា ៥
-ប្រាក់ឧបត្ថម្ភគ្រូបង្វឹក និងគ្រូជំនួយ អនុវត្តដូចមាត្រា ៦ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១២**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ